# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: 259 ប្រក.កសក

## ប្រ កា ស

ស្តីពី

## ការហាមឃាត់ក្នុងការប្រើប្រាស់ឧបករណ៍ឆក់ត្រី ឧបករណ៍នេសាទអួនក្រឡាញឹក និង ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ នៅក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា

### រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញ ក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានឃើញ អនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញ ប្រកាសលេខ ០២៨ កសក ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ១៩៨៧ ស្តីពីការកំណត់ឧបករណ៍នេសាទដែលអនុញ្ញាតឱ្យធ្វើអាជីវកម្មក្នុងដែននេសាទទឹកសាប និង សមុទ្រ
- តាមសំណើរបស់ នាយកដ្ឋានជលផល

## ស ំ រេ ច

**ប្រការ១** : ហាមដាច់ខាតការធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍ឆក់ត្រី ឧបករណ៍នេសាទអួនក្រឡាញឹកដែលមានក្រឡាតូចជាង ១,៥សង្ទីម៉ែត្រ និង ឧបករណ៍នេសាទស្បៃមុងគ្រប់ប្រភេទ នៅក្នុងដែននេសាទទឹកសាប នៃព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ២** : ហាមដាច់ខាត ការដឹកជញ្ជូន ការទិញ ការលក់ ការរក្សាទុក និង/ឬសន្និធិប្រភេទធនធានជលផល ដែលបានមកពីការធ្វើនេសាទល្មើសច្បាប់ ដោយឧបករណ៍នេសាទអួនក្រឡាញីក និង ឧបករណ៍នេសាទ ស្បៃមុងគ្រប់ប្រភេទ ។

**ប្រការ៣** : ជនណាដែលបានប្រព្រឹត្តល្មើសនឹងប្រការ១ ឬ/និង ប្រការ២ នៃប្រកាសនេះ ត្រូវផ្តន្ទាទោសតាម មាត្រា៣៨ មាត្រា៣៩ ឬ មាត្រា៤០ នៃក្រឹត្យ-ច្បាប់លេខ ៣៣ ក្រ.ច ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល ។

**ប្រការ៤** : ជនណាឆ្លៀតយកឥទ្ធិពល និង អំណាចនៅក្នុងមុខងាររបស់ខ្លួន ដើម្បីប្រព្រឹត្តបទល្មើស ឬ ឃុបឃិត បិទបាំង ការពារអំពើល្មើស ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន ។

**ប្រការ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦** : អគ្គនាយក នៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាន នាយកដ្ឋាន កិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការ ស្ថិតិ និងសហប្រតិបត្តិការ អន្តរជាតិ ប្រធាន នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានជលផល ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្ត ក្រុង និងប្រធានការិយាល័យជលផលខេត្ត ក្រុង ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី 12 ខែ សីហា ឆ្នាំ ២០០២

រដ្ឋមន្ត្រី

ចៅ សារ៉ាត

**កន្លែងទទួល** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងយុត្តិធម៌
- សាលាខេត្ត ក្រុង ពាក់ព័ន្ធ
- ដូចប្រការ៦
- ឯកសារ-កាលប្បវត្តិ